**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកឧត្តម Ri Kil Song អនុរដ្ឋមន្ត្រីការបរទេស ស.ប.ប.កូរ៉េ ចូលជួបសម្តែងការគួរសម**

នៅរសៀលទី **១៥** ខែ **វិច្ឆិកា** ឆ្នាំ២០១៩ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអនុញ្ញាតឲ្យឯកឧត្តម Ri Kil Song អនុរដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ(ស.ប.ប.កូរ៉េ) ទទួលបន្ទុកកិច្ចការអាស៊ី ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍ចំពោះដំណើរទស្សនកិច្ចលើកដំបូង នៅកម្ពុជារបស់**ឯកឧត្តម** Ri Kil Song ក្នុងនាមជាអនុរដ្ឋមន្ត្រីការបរទេស ដែលស្របគ្នានឹងឱកាសខួបលើកទី៥៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសំដែងអំណរគុណចំពោះឯកឧត្តមអនុរដ្ឋមន្ត្រីអំពីប្រការដែល**ឯកឧត្តម គីម ជុងអ៊ុន** ប្រធានគណៈកម្មការកិច្ចការរដ្ឋនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ បានផ្ញើលិខិតអបអរសាទរថ្វាយ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបទី៦៦ ទិវាបុណ្យឯករាជ្យជាតិរបស់កម្ពុជា ដែលបានបង្ហាញនូវមិត្តភាពរវាងថ្នាក់ដឹកនាំ និងប្រជាជននៃប្រទេសទាំងពីរ។

ជាការឆ្លើយតប ឯកឧត្តម Ri Kil Song បានថ្លែងអំណរគុណដល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីចំពោះកិច្ចស្វាគមន៍ និងបដិសណ្ឋារកិច្ចកក់ក្តៅដល់ឯកឧត្តម និងប្រតិភូអមដំណើរ។ ឯកឧត្តម Ri Kil Song សម្តែងការអបអរសាទរចំពោះវឌ្ឍនភាពសេដ្ឋកិច្ចសង្គមកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងលទ្ធផលនៃការបោះឆ្នោតនៅកម្ពុជាកាលពីឆ្នាំ ២០១៨។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** យល់ស្របមតិរបស់ឯកឧត្តម Ri Kil Song អំពីសារសំខាន់នៃការបន្តជម្រុញទំនាក់ទំនាក់ល្អ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ហើយបានទទួលយកការអញ្ជើញឯកឧត្តមទៅបំពេញទស្សនកិច្ចនៅស.ប.ប.កូរ៉េ ក្នុងពេលវេលាសមស្រប។

ក្នុងឱកាសជំនួបនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជំរាបជូនឯកឧត្តម Ri Kil Song អំពីការអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងស.ប.ប.កូរ៉េ ដែលនេះជាកាតព្វកិច្ចរបស់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិទាំងអស់។

សូមបញ្ជាក់ផងដែរថា មុនជំនួបសម្តែងការគួរសមជាមួយ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ឯកឧត្តម Ri Kil Song បានពិភាក្សាការងារជាមួយសមភាគីកម្ពុជា លោកជំទាវ អ៊ាត សោភា រដ្ឋលេខាធិការ

នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងកម្ពុជា និងស.ប.ប.កូរ៉េ ។

សូមរំលឹកថា ព្រះករុណា **សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ** អតីតព្រះមហាក្សត្រកម្ពុជា និង **ឯកឧត្តមសេនាប្រមុខ គីម អ៊ីលស៊ុង** បានសម្រេចឲ្យមានការតភ្ជាប់ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ជាផ្លូវការនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៦៤។

ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៩